ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៦-៧-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៤៧ ស្តីពីការអនុញ្ញាតអោយលោកជំទាវ **ជូ ម៉ុនអេង** មន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ចូលបំរើការងារឡើងវិញ ១៦២៩

២៦-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៤៨ ស្តីពីការ តម្លើងឋានៈជូនឯកឧត្តម លោកជំទាវ ជានាយករង ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន ១១ រូប ១៦៣០

២៨-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៤៩ ស្តីពីការតែងតាំងសមាជិក សមាជិកា ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាសំរាប់នីតិកាលទី ១ ១៦៣២

២៨-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥០ ស្តីពីការតែងតាំងឯកឧត្តម **យ៉ង់ សែម** សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាសំរាប់នីតិកាលទី ១ ជំនួសឯកឧត្តម **អ៊ុក ប្រាថ្នា** ១៦៣៣

២៨-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥១ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុំ ម៉ុនអាង** សមាជិក ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាសំរាប់នីតិកាលទី ១ ជំនួសឯកឧត្តម **អ៊ី ម៉ុនឡុង** ១៦៣៤

២៨-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥២ស្តីពីការបញ្ចប់តំណែងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា គ្រប់រូប ដែលបានទទួលការតែងតាំងមុនថ្ងៃ ទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ និងតែងតាំងឥស្សរជន ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ១៦៣៥

២៨-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥៣ ស្តីពីការតែងតាំងឯកឧត្តម **ឈួន សុធី** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ១៦៣៧

២៨-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥៤ ត្រូវបានតម្លើងឋានៈជូនលោកជំទាវ ជាជំនួយការនាយក ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន ០២ រូប ១៦៣៨

២៩-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥៥ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯកជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ១៦៣៩

២៩-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥៦ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ១៦៤០

២៩-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥៧ ស្តីពីការតែងតាំង ឯកឧត្តម **ឡុញ ហ៊ារ៉ល** ជាអគ្គនាយក នៃ អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន ១៦៤១

២៩-៧-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១៥៨ ស្តីពីការតែងតាំង ឯកឧត្តម **ណរាក សាខន** ជាអគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ១៦៤២

០២-៨-២០០៤ - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/១៩៩ ស្ដីពីការតែងតាំងឯកឧត្ដមសាស្ត្រាចារ្យមហាបរិញ្ញាប័ត្រ **ក្លូត ហ្គួរ** (CLAUDE GOUR) ជាទីប្រឹក្សាច្បាប់អមរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសហប្រតិបត្តិការនីតិកម្ម ជាមួយសាធារណរដ្ឋបារាំង ១៦៤៣

## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

២៦-៧-២០០៤ - អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្ដីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ១៦៤៤
២៨-៧-២០០៤ - អនុក្រឹត្យលេខ ៣១ អនក្រ.បក ស្ដីពីការកែសំរួលរចនាសម្ព័ន្ធ និងប្ដូរឈ្មោះខុទ្ទកាល័យក្រសួងការពារ ជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ ១៦៤៦
២៨-៧-២០០៤ - អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្ដីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ ១៦៥១
២៦-៧-២០០៤ - អនុក្រឹត្យលេខ ៤៣៧ អនក្រ.តត ស្ដីពីការផ្ទេរមុខងារនាយទាហានជាន់ខ្ពស់ ១៦៥៤
២៦-៧-២០០៤ - អនុក្រឹត្យលេខ ៤៣៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៥៥
២៦-៧-២០០៤ - អនុក្រឹត្យលេខ ៤៣៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៥៦
២៦-៧-២០០៤ - អនុក្រឹត្យលេខ ៤៤០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៥៧
២៦-៧-២០០៤ - អនុក្រឹត្យលេខ ៤៤១ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៥៨
២៧-៧-២០០៤ - អនុក្រឹត្យលេខ ៤៤២ អនក្រ.តត ស្ដីពីការ តម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១៦៥៩
២៨-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៣ អនក្រ.តត ស្ដីពីការតែងតាំងមុខងារនាយទាហាន ១៦៦០
២៨-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៤ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ១៦៦៣
២៨-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៦៤
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៦ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៦៥
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៦៦
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៦៧
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៤៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៦៨
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៥០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៦៩
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៥១ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៧០
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៥២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៧១
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៥៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៧២
៣០-៧-២០០៤ - អនុក្រឹត្យលេខ ៤៥៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១៦៧៣

## ២_ សេចក្តីសំរេច

២៦-៧-២០០៤ - សេចក្តីសំរេចលេខ ៤៤សសរ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ឯកជន ១៦៧៤

## ៣_ សារាចរណែនាំ

០១-៣-២០០៤ - សារាចរណែនាំលេខ ០២ សរណន ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ១៦៧៧

០៦-៤-២០០៤ - សារាចរណែនាំលេខ ០៣សរណន ស្តីពីការការពារសន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ ការទប់ស្កាត់ និងការបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ វកនស័ក ព.ស ២៥៤៨ត្រូវនឹងថ្ងៃទី ១៣ ទី ១៤និងទី ១៥ ខែមេសា ឆ្នាំ ២០០៤ ១៦៧៩

០២៧-៤-២០០៤ - សារាចរណែនាំលេខ ០៤ សរណន ស្តីពីការ ចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១១៨ ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ២០០៤ ១៦៨១

១៤-៥-២០០៤ - សារាចរណែនាំលេខ ០៥ សរណន ស្តីពីការ រៀបចំខួបលើកទី ១៥ ទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនិងពលកម្មកុមារ ១២ មិថុនា" ១៦៨៣

០៦-៧-២០០៤ - សារាចរណែនាំលេខ ០៦សរណន ស្តីពីការទប់ស្កាត់និងលុបបំបាត់ការលួចបន្លំស្បៀងពលកម្មរបស់អង្គការ ស្បៀងអាហារពិភពលោក ១៦៨៥

# III- ការិយាល័យក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-០៧-២០០៤ - ប្រកាសលេខ ២១៨ សហវ.ប្រក ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១៦៨៧

២៨-០៧-២០០៤ - ប្រកាសលេខ ២២០ សហវ.ប្រក ស្តីពីការបង្កើត ក្រុមការងារសំរាប់ប្រមូលចំណូលមិនមែនសារពើពន្ធ ក្រៅពីទ្រព្យរដ្ឋ និងឧស្សាហកម្មហិរញ្ញវត្ថុ ១៦៩២

## ៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៨-០៧-២០០៤ - ប្រកាសលេខ ១៤៤ MOC/ M 2004 ស្តីពីលទ្ធផល នៃការដេញថ្លៃកូតាសំរាប់នាំចេញសំលៀកបំពាក់ទៅ កាន់ សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤ ១៦៩៤

28-7-2004 - PRAKAS N° 144 MOC/ M 2004 On the result of Tender for the Quota on Garments to be explored to the United States of America in FY 2004 ១៦៩៦

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៤/១៤៧

យើង

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩៩៦/១០ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : អនុញ្ញាតអោយលោកជំទាវ ឌូ ម៉ិនអេង មន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ចូលបំរើការងារឡើងវិញ ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៣ នេះតទៅ ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២៦ ខែ០៧ ឆ្នាំ២០០៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ពរស. ០៤.០៧.១៤៥

លេខៈ ១៦៣ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤/១៤៤

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូនឯកឧត្តម លោកជំទាវ ជា **នាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា** ដែលមានរាយនាមដូចខាងក្រោម :

១-លោកជំទាវ **ម៉ាត់លីវុន គន្ធាឫទ្ធី** នាយិការពិធីការ ឋានៈស្មើ **រដ្ឋលេខាធិការ** ។

២-លោកជំទាវ **ឡោក ខេង** នាយករងខុទ្ទកាល័យទទួលបន្ទុកប្រធានមូលនិធិខ្មែរអភិវឌ្ឍន៍ ឋានៈស្មើ **រដ្ឋលេខាធិការ** ។

៣-លោកជំទាវ **ជា សំអេង** នាយករងខុទ្ទកាល័យទទួលការងារមូលនិធិខ្មែរអភិវឌ្ឍន៍ ឋានៈស្មើ **រដ្ឋលេខាធិការ** ។

៤-លោកជំទាវ **ជា ពីន** នាយករងខុទ្ទកាល័យទទួលការងារមូលនិធិខ្មែរអភិវឌ្ឍន៍ ឋានៈស្មើ **រដ្ឋលេខាធិការ** ។

៥-ឯកឧត្តម **ម៉ិន ឌូឡា** នាយករងខុទ្ទកាល័យទទួលបន្ទុកកិច្ចការរដ្ឋបាល ឋានៈស្មើ **រដ្ឋលេខាធិការ** ។

៦-ឯកឧត្តម **ឡោក ឈួរ** នាយករងខុទ្ទកាល័យទទួលបន្ទុកការងារអភិវឌ្ឍន៍ ឋានៈស្មើ **រដ្ឋលេខាធិការ** ។

៧-ឯកឧត្តមឧត្តមសេនីយ៍ទោ **ឃឹម លាង** នាយករងខុទ្ទកាល័យទទួលបន្ទុកការការពារសន្តិសុខ និង ពតិហាន ឋានៈស្មើ **រដ្ឋលេខាធិការ** ។

៨-ឯកឧត្តម **ម៉ក់ ឌីជិត** នាយករងខុទ្ទកាល័យទទួលបន្ទុកទំនាក់ទំនងទូទៅ ឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

៩-ឯកឧត្តម **ជា សុធន** នាយករងខុទ្ទកាល័យទទួលបន្ទុកផ្នែកនីតិកម្ម ឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

១០-ឯកឧត្តម **ជា សុមេធី** នាយករងខុទ្ទកាល័យទទួលបន្ទុកទំនាក់ទំនងទីប្រឹក្សា ឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

១១-ឯកឧត្តម **ងិម សុនី** ប្រធាននាយកដ្ឋានទទួលបន្ទុកលេខាធិការ ឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០០៤

**ឆ្លងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ពរក.០៤.០៧.១៤៩

លេខ: ១០៧ ធ.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាឌី តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៤៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៩ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចក្រុមឃុន ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស ប្រធានព្រឹទ្ធសភាស្តីទី

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំង

១-សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រ-កម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម ជា ម៉េងឃាង ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

២-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម សៅរី ភូសល ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

៣-ឯកឧត្តម រស់ ឆេង ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលតី១ ជំនួសឯកឧត្តម ខៀវ សន ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

៤-អ្នកម្នាង នរោត្តម ឌីយ៉ាត ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម ស៊ឹម សូលី ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

៥-ឯកឧត្តម ហួត ម៉ុងលី ជាសមាជិកព្រឹទ្ធសភានៃ ព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម ស៊ិន ពិនសេន ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

មាត្រា ២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ២០០៤

គួរព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ចករ

ជា ស៊ីម

៣៣ល.០៤.០៧.១៥០

លេខ: ១១៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ស៊ាន

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៥០

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៩ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ស្តេចក្រុមឃុន ស៊ីសុវត្ថិ ជីវ័ន្តមុនីរ័ក្ស ប្រធានព្រឹទ្ធសភាស្តីទី

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម **យ៉ែម សែម** ជាសមាជិក ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម **អ៊ុក ប្រាជ្ញា** ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

មាត្រា ២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៤

**ថ្វាយព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

[illegible] លេខ: ១១៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញៈថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សូណា ទី ឥាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៩១

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៥ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ស្តេចក្រុមឃុន ស៊ីសុវត្ថិ ជីវ័ន់មុនីរក្ស ប្រធានព្រឹទ្ធសភាស្តីទី

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **អ៊ឹង ប៊ុនអេង** ជាសមាជិក ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម **អ៊ឹង ប៊ុនឡុង** ដែលបានលាលែងទៅទទួលភារកិច្ចថ្មី ។

**មាត្រា ២:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ២០០៤

**ត្ថុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ទារ.០៤.០៧.១២៤

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

លេខ: ១១៥ ច.ល

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារ៉ាធី ទាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៤/១៩៦

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានបញ្ចប់តំណែងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជាគ្រប់រូប ដែលបានទទួលការតែងតាំង មុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ។

**មាត្រា ២.-**

ត្រូវបានតែងតាំងឥស្សរជនជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | ហោង | វង្សប៊ុនឆាត | ឋានៈស្មើ | ទេសរដ្ឋមន្ត្រី |
| ២- | ឯកឧត្តម | ទា | ចំរ៉ាត់ | ឋានៈស្មើ | ទេសរដ្ឋមន្ត្រី |

| | | | | | |
|---|---|---|---|---|---|
| ៣- | ឯកឧត្តម | ឈឹម | ឱមយ៉ុន | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ៤- | ឯកឧត្តម | ប៉ែន | ថុល | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ៥- | ឯកឧត្តម | អៀង | មូលី | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ៦- | ឯកឧត្តម | វ៉ា | គឹមហុង | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ៧- | ឯកឧត្តម | សុន | គន្ធរ | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ៨- | ឯកឧត្តម | ដួង | ខែម | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ៩- | ឯកឧត្តម | ស៊ុំ | ម៉ានិត | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ១០- | ឯកឧត្តម | អ៊ុក | ភូរិ | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ១១- | ឯកឧត្តម | ព្រហ្ម | ញាណវិចិត្រ | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ១២- | ឯកឧត្តម | ឆយ | យីហ៊ាង | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ១៣- | ឯកឧត្តម | យឹម | ណូឡា | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ១៤- | ឯកឧត្តម | សុខ | ឥសាន | ឋានៈស្មើ | រដ្ឋមន្ត្រី |
| ១៥- | ឯកឧត្តម | ម៉ៃ | សំអឿន | ឋានៈស្មើ | រដ្ឋលេខាធិការ |
| ១៦- | ឯកឧត្តម | អ៊ុន | វិសារ៉ុំ | ឋានៈស្មើ | រដ្ឋលេខាធិការ |
| ១៧- | ឯកឧត្តម | ទូ | សាំងខន | ឋានៈស្មើ | រដ្ឋលេខាធិការ |

**មាត្រា ៣.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

នស.០៤.០៧.១៥៣

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ: ១១៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សូរ៉ាទី គាន់**

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៧០៤/១៥៣

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានតែងតាំង ឯកឧត្តម ឈួន សុធី ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

កាល.០៤.០៧.១៥៤

លេខ: ៦១៦ ច.ល

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សៅ ឌី តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន លោកជំទាវ ជា ជំនួយការនាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួនពីររូបដូចមានរាយនាមខាងក្រោម :

១-លោកជំទាវ ជា ផល្លណ ឋានៈស្មើ អគ្គនាយក ។

២-លោកជំទាវ ជា សុផាម៉ាដែន ឋានៈស្មើ អគ្គនាយក ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

ពរល.០៤.០៧.១៥៥

លេខ: ១៧១ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាអី គាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៩៥

យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត / ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- ឧត្តមសេនីយ៍ទោ ប៉ែន អ៊ាន អត្តលេខ ០០៤១

២- ឧត្តមសេនីយ៍ទោ សៅ រ៉ានី អត្តលេខ ០៤០៤

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០៤*

*ក្នុងព្រះបរមនាម និង តាមព្រះរាជក្រាស់បង្គាប់*

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤.០៧.១៩៦

លេខៈ ១៧២ ចម

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ក.ក ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៥៦

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :**

តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ឯក គឹម ណាន អត្តលេខៈ ០៣៥០ ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

២- លោកវរសេនីយ៍ឯក គាំ សុខុន អត្តលេខៈ ០៣៥១ ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

**មាត្រា ២ :**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

៣រល.០៤.០៧.១៥៧

លេខៈ ១៦៧០ ចល

ដើម្បីចម្លងចែក ហត្ថលេខា និងព្រះរាជលញ្ឆករ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ០៧ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាវី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៩៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ឡុញ ចិរាល ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ចរស.០៤.០៧.១៩៨

លេខ: ១៧២៤ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ៧ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៤ / ១៥៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ណារាក សាខន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣ល-០៤-០៧-១៥៩

លេខៈ ១៧៣ ចល

ច្បាប់ចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ៧ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/១៥៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម សាស្ត្រាចារ្យមហាបរិញ្ញាប័ត្រ ក្លូត ហ្គួរ (CLAUDE GOUR) ជាទីប្រឹក្សាច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសហប្រតិបត្តិការនីតិកម្មជាមួយសាធារណរដ្ឋបារាំង មានឋានៈស្មើរដ្ឋមន្ត្រី ។

**មាត្រា ២.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែសីហាឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤.០៨.១៦០ លេខ ២៤៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៣០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរចាំបាច់

## សំរេច

**មាត្រា ១** : ត្រូវបានបង្កើត ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ហៅកាត់ថា " ក.ស.ស.ស " ។

**មាត្រា ២** : សមាសភាពនៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៣** : ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានភារកិច្ច ដូចតទៅ ៖

- សិក្សាស្រាវជ្រាវ និងប្រមូលពត៌មានដើម្បីធ្វើការវិភាគ និងវាយតម្លៃអំពីស្ថានភាព និងការវិវត្តន៍លើ វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅព្រះរាជាណាចក្រកម្ពុជា
- វិភាគ និងវាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ច ស្ថានភាពការងារ និងធុរៈកិច្ច សកម្មភាពផលិតកម្ម អាជីវកម្ម សេវាកម្មនានា សមតាសេដ្ឋកិច្ចក្រៅប្រទេស តុល្យភាពថវិកា

- វិភាគ និងវាយតម្លៃអំពីស្ថានភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ លើផ្នែកសំភារៈ និងស្មារតី ស្ថានភាពសង្គមកិច្ច សុខាភិបាល អប់រំ និង វប្បធម៌
- សហការជិតស្និទ្ធក្នុងការផ្លាស់ប្តូរព័ត៌មាន និងបច្ចេកទេសជាមួយក្រសួង ស្ថាប័នជាតិ ផ្នែកឯកជន ឬអង្គការអន្តរជាតិផ្សេងៗលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ធ្វើរបាយការណ៍ វាយតម្លៃ និងផ្តល់យោបល់អំពីស្ថានការកំណត់គោលដៅ ជ្រើសរើសវិធានការ និងរិះរកមធ្យោបាយដោះស្រាយបញ្ហាផ្សេងៗ លើការងារពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ អោយបានឆាប់រហ័សទាន់សភាពការណ៍ និងទៀងទាត់តាមកាលកំណត់ ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៤** : - ក.ស.ស.ស. មានអគ្គលេខាធិការដ្ឋានជាជំនួយការ ហើយមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- អគ្គលេខាធិការដ្ឋាននៃ ក.ស.ស.ស. ដឹកនាំដោយអគ្គលេខាធិការមួយរូប ទទួលបន្ទុកកិច្ចការរដ្ឋបាល ថវិកា និងការរៀបចំឯកសារទូទៅ
- អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់
- អគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក
- ប្រធានផ្នែកជំនាញ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានមន្ត្រីជំនាញមួយចំនួនជាជំនួយការ ។

**មាត្រា ៥** : ក.ស.ស.ស. ធ្វើការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ឬតាមបញ្ជារបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រធានអាចអញ្ជើញអ្នកមានសមត្ថកិច្ចផ្សេងៗនៃក្រសួង ស្ថាប័ន ចូលមកបំភ្លឺ ចូលរួមកិច្ចប្រជុំការងារ ឬសិក្សាលើឯកសារពាក់ព័ន្ធ ។

ក.ស.ស.ស. មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦** : អនុក្រឹត្យលេខ ០៥ អនក្រ.តត ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន ពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកត / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១.-**

ត្រូវបានកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ ដែលមានខុទ្ទកាល័យរដ្ឋមន្ត្រី និងនាយកដ្ឋានបីចំណុះដូចខាងក្រោម :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានតម្កល់ឯកសារ
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានសរុប

**មាត្រា២ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រីមានតួនាទី និងភារកិច្ចដូចមានចែងក្នុង មាត្រា១៧ ជំពូកទី ៦នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

**មាត្រា៣ .-**

នាយកដ្ឋានតម្កល់ឯកសារ មានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- តម្កល់រាល់លិខិតស្នាម ឯកសារ កិច្ចព្រមព្រៀងយោធា និងឯកសារផ្សេងទៀត ។
- រក្សាសុវត្ថិភាព និងការពារសំងាត់រាល់ឯកសារ
- ប្រមូលឯកសារតាមបណ្តាស្ថាប័ន កងឯកភាព ក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីចងក្រង និងតម្កល់ទុកក្នុងបណ្ណាសារដ្ឋានក្រសួងការពារជាតិ ។

**មាត្រា៤.-**

នាយកដ្ឋានតម្កល់ឯកសារ ត្រូវបានដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

**មាត្រា៥ .-**

នាយកដ្ឋានកិច្ចការរដ្ឋបាល មានតួនាទី និង ភារកិច្ច :

- ជាខ្សែរយៈសម្រាប់ ទំនាក់ទំនង សំរបសំរួល ទទួល និងបញ្ជូនលិខិតស្នាម រវាងក្រសួងការពារជាតិ ជាមួយ ស្ថាប័នកងឯកភាពយោធា ក្រោមឱវាទរបស់ក្រសួងការពារជាតិ បណ្តាស្ថាប័នស៊ីវិលចំណុះរាជរដ្ឋាភិបាល ស្ថាប័នព្រឹទ្ធសភា-រដ្ឋសភា និងអង្គការនានា ។
- អនុវត្ត និងណែនាំ លើវិស័យរដ្ឋបាលទូទាំងកងយោធពលខេមរភូមិន្ទ និងធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាលឱ្យបានទាន់ពេលវេលា ។
- ធ្វើការផ្សព្វផ្សាយរាល់ លិខិតស្នាម លិខិតបទដ្ឋានទាំងឡាយរបស់ក្រសួងការពារជាតិ និងស្ថាប័នផ្សេងៗទៀត ដែលបានសម្រេចប្រកាសឱ្យប្រើជាសាធារណៈ ។
- មានភារកិច្ចពិនិត្យ ពិចារណាលើលិខិតស្នាមឱ្យបានត្រឹមត្រូវ តាមបែបបទរដ្ឋបាល តាមឋានានុក្រម ដាក់កំណត់បង្ហាញ សង្ខេបខ្លឹមសារអត្ថបទ ដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ សម្រេច តាមឋានានុក្រម ។

- សរសេរលិខិតអញ្ជើញចូលរួមប្រជុំ ចូលរួមក្នុងពិធីផ្សេងៗ លិខិតបញ្ជាបេសកកម្ម អនុញ្ញាតច្បាប់ និងបង្គាប់ការ ។
- រៀបចំបោះពុម្ពលិខិតស្នាមផ្សេងៗ សម្រាប់ដំណើរការការងារ ឱ្យប្រព្រឹត្តទៅតាមទំរង់បែបបទរដ្ឋបាល ។
- សហការរៀបចំទិវាបុណ្យជាតិ អន្តរជាតិ រៀបចំទីកន្លែងប្រារព្ធពិធីផ្សេងៗ ដូចជា កន្លែងប្រជុំមិទ្ទីញ សន្និបាតរបស់ក្រសួង ។

**មាត្រា៦ .-**

នាយកដ្ឋានកិច្ចការរដ្ឋបាល ត្រូវបានដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

**មាត្រា៧ .-**

នាយកដ្ឋានសរុប មានតួនាទី និងភារកិច្ច :

- ទទួល និងធ្វើការពិចារណានូវរាល់លិខិតស្នាម ពីស្ថាប័ននានា និងកងឯកភាពក្នុងកងយោធពលខេមរភូមិន្ទដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំ ពិនិត្យ សម្រេច ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងអត្ថបទ កែសំរួលលិខិតស្នាម លិខិតបទដ្ឋានរបស់ក្រសួងឱ្យបានត្រឹមត្រូវ តាមបែបបទរដ្ឋបាល និងគោលការណ៍របស់ថ្នាក់លើ ។
- រៀបចំចាត់ចែង ធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងលើកទិសដៅការងាររួមប្រចាំខែ ត្រីមាស ឆមាស ៩ខែ ឆ្នាំ របស់ក្រសួង រាយការណ៍ ជូនរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ។
- ធ្វើកំណត់ហេតុរាល់ពេលប្រជុំរបស់ក្រសួង ធ្វើសេចក្តីជូនដំណឹងទៅស្ថាប័នពាក់ព័ន្ធ តាមស្មារតីសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង ។
- សហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដានក្តាប់សភាពការណ៍វិវត្តន៍ ក្នុងកងយោធពលខេមរភូមិន្ទដើម្បីមានមូលដ្ឋានធ្វើការបូកសរុប ។
- ធ្វើជាសេនាធិការ ជូនថ្នាក់ដឹកនាំក្រសួងការពារជាតិ ត្រួតពិនិត្យតាមដានអំពីប្រសិទ្ធភាព នៃការអនុវត្តការងារលិខិតស្នាម ។
- ទទួលរាល់លិខិតស្នាមពីគ្រប់ស្ថាប័ន កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ដែលទាក់ទងទៅនឹងសំណើសុំបញ្ជាក់ និងចុះហត្ថលេខា ពីថ្នាក់ដឹកនាំក្រសួងការពារជាតិ ។

**មាត្រា ៨ .-**

នាយកដ្ឋានសរុប ត្រូវបានដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

**មាត្រា ៩ .-**

ការរៀបចំ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ចំណុះនាយកដ្ឋានតម្កល់ឯកសារ នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានសរុប ត្រូវកំណត់ដោយ ប្រកាសរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា១០ .-**

មាត្រា ៤ ចំណុចទី ១ ត្រង់ទី ១ ស្តីពីខុទ្ទកាល័យ និងមាត្រា ៥ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្ត អនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤*

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ** **ហ៊ុន សែន**

**ទៀ បាញ់** **ញឹក ប៊ុនឆៃ**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- លេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.............. អនក្រ.បក

ចុះថ្ងៃទី ខែ ឆ្នាំ២០០៤

## អង្គការលេខ របស់អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ




ញ. ប្ញក់

នាយឧ.ផ្កាយមាស៥ ឆៅ-ប៉ុណ្ណា នាយឧ.ផ្កាយមាស៤ញឹក-ប៊ុនឆៃ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

~~~~~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពរចាំបាច់

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា ២.-**

សមាសភាពនៃក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។
~~~~~~~

**មាត្រា៣.-**

ក្រុមប្រឹក្សាអ្នកច្បាប់ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានភារកិច្ចដូចតទៅ ÷

-សិក្សាស្រាវជ្រាវ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងដៃគូឯកជន ដើម្បីលើកគំរោងកសាងច្បាប់ ឬ លិខិតបទដ្ឋានថ្មីៗ ដែលមានការចាំបាច់សំរាប់បំរើអោយសកម្មភាពរាជរដ្ឋាភិបាល

-ទំនាក់ទំនង សំរបសំរួល និងផ្តល់យោបល់ដល់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការតាក់តែងច្បាប់ និងលិខិតបទដ្ឋានអោយស្របតាមអាទិភាពនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

-សិក្សា និងតាមដានអត្ថបទច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលត្រូវបានប្រកាសចេញអោយប្រើ ដែលលែងសមស្របនឹងសភាពការណ៍ជាក់ស្តែង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលធ្វើវិសោធនកម្ម អោយទាន់ពេលវេលា និងស្របតាមស្ថានភាពវិវត្តន៍នៃប្រទេសជាតិ

-សិក្សា និងផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រី អំពីសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយជាមួយអន្តរជាតិ ដែលបណ្តាក្រសួង ស្ថាប័នផ្ញើមកសុំសេចក្តីសំរេចពីគណៈរដ្ឋមន្ត្រី

-តាមដាន ឃ្លាំមើលលើការអនុវត្ត និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន

-ជួយទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការសហការជាមួយក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចក្នុងការចាត់ចែងផ្ញើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានទៅជូនស្ថាប័ន ដែលមានសមត្ថកិច្ចផ្តល់សច្ចាប័នជាចុងក្រោយអោយបានសមស្របតាមនីតិវិធី

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាអ្នកច្បាប់ តាមកាលកំណត់អោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤ .-**

-ក្រុមប្រឹក្សាអ្នកច្បាប់ មានអគ្គលេខាធិការដ្ឋានជាជំនួយការ និងមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអ្នកច្បាប់ដឹកនាំដោយអគ្គលេខាធិការមួយរូប ទទួលបន្ទុកកិច្ចការ រដ្ឋបាល ថវិកា និងការរៀបចំ គ្រប់គ្រងឯកសារទូទៅ

-អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់

-អគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក

-ប្រធានផ្នែកជំនាញ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានមន្ត្រីមួយចំនួនជាជំនួយការ ។

**មាត្រា៥ ..**

ក្រុមប្រឹក្សាអ្នកច្បាប់ ធ្វើការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន

ប្រធានអាចអញ្ជើញអ្នកមានសមត្ថកិច្ចផ្សេងៗ នៃក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន អោយចូលមកបំភ្លឺ ចូលរួមកិច្ចប្រជុំការងារ ឬសិក្សាលើឯកសារពាក់ព័ន្ធ

ក្រុមប្រឹក្សាអ្នកច្បាប់ ចូលរួមប្រជុំអន្តរក្រសួង និងសហការជាមួយអគ្គលេខាធិការរាជរដ្ឋាភិបាល ក្នុងកិច្ចការដែលពាក់ព័ន្ធនឹងច្បាប់ លិខិតបទដ្ឋាននានា ដែលក្រសួង ស្ថាប័នបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី

ក្រុមប្រឹក្សាអ្នកច្បាប់ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៦ ..**

អនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៧

-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៣៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការផ្ទេរមុខងារនាយទាហានជាន់ខ្ពស់

៣ ៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលបេសកកម្មទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១** : ត្រូវបានផ្ទេរមុខងារឧត្តមសេនីយ៍ឯក **តួន ស៊ីផាន** អត្តលេខ ០០០០៩១ នាយរងសេនាធិការចំរុះ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អោយមកជានាយទាហានបំរើនៅក្រសួងការពារជាតិ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ [illegible] កក្កដា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣៧ - អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## សំរេច

**មាត្រា ១ :** តែងតាំងមន្ត្រី ០៣ រូប របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដូចមានរាយនាមខាងក្រោម ៖

១_លោក សែ សាមុត ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់

២_លោក នុត ពុធដារ៉ា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល

៣_លោក ឡៅ និទ្ទសីហា ជាប្រធាននាយកដ្ឋានសំណង់ នៃអគ្គនាយកដ្ឋានសំណង់

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំរេច

**មាត្រា ១** : តែងតាំងមន្ត្រី ០៤ រូប របស់ក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ៖

១_លោក សំ ខាន់ឌី ជាអគ្គនាយករងបច្ចេកទេស

២_លោក ស៊ុ សាធុន ជាប្រធាននាយកដ្ឋានអប់រំពិតមាន និង ផ្សព្វផ្សាយបរិស្ថាន

៣_លោក ជួន ច័ន្ទរិទ្ធី ជាប្រធាននាយកដ្ឋានវាយតម្លៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យ

៤_លោកស្រី ជូ សុខដានី ជាប្រធាននាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ២** : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៤០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ .

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

-យោងតាមសភាពការណ៍ចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

# សម្រេច

**មាត្រា១.**

តែងតាំង លោក **ចាន់ ដារ៉ុន** ជាអគ្គនាយករងបច្ចេកទេស នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ។

**មាត្រា២.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៣
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៤១ . អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

### សម្រេច

**មាត្រា១.-**

តែងតាំងលោក **ឱ្យយ រី** ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសប៊ែលហ្ស៊ិក។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤២ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរៈសេនីយ៍ទោ ស៊ិន ស៊ីណារ៉េត អត្តលេខ ០៥៣៥ ។
២-លោកវរៈសេនីយ៍ទោ លឹម ឡឿន អត្តលេខ ០៧១៦ ។
៣-លោកវរៈសេនីយ៍ទោ ឆាយ សុវណ្ណ អត្តលេខ ០៧៤៧ ។
៤-លោកវរៈសេនីយ៍ទោ ឈួន សុជេង អត្តលេខ ០៧៤៧៩ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ខែ [illegible]ដា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤៣. អនក្រ. បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខងារនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងមុខងារ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាម ដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ទោ **នរោត្តម ប៉ាកប៉ានី** អត្តលេខ ០០០០៣៤ ទីប្រឹក្សា អគ្គមេបញ្ជាការ បច្ចុប្បន្នជា ទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ទោ **ចាប តូនី** អត្តលេខ ០០០៣៨៩ នាយទាហានរង់ចាំការងារ ទីចាត់ការបុគ្គលិក បច្ចុប្បន្នជា ទីប្រឹក្សាក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ទោ **ហោច ហួច** អត្តលេខ ០០០១២៧ អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស បច្ចុប្បន្នជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

| | | | |
|---|---|---|---|
| ៤-ឧត្តមសេនីយ៍ទោ | ជុំ | ហាត់ | អត្តលេខ ០០០២៧២ នាយសេនាធិការរង កងទ័ពជើងគោក និងជា នាយការិយាល័យទី២ បច្ចុប្បន្នជា មេបញ្ជាការរង កងទ័ពជើងគោក |
| ៥-ឧត្តមសេនីយ៍ត្រី | ម៉ាង | ធី | អត្តលេខ ០០០១៩៧ នាយទាហានរង់ចាំការងារ ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា ទីប្រឹក្សាក្រសួងការពារជាតិ |
| ៦-ឧត្តមសេនីយ៍ត្រី | សួន | សំណាង | អគ្គលេខ ០០០២០៦ នាយករង នាយកដ្ឋាន ទាក់ទងអន្តរជាតិ បច្ចុប្បន្នជា អគ្គនាយករង អគ្គនាយកដ្ឋាន យោធសេវា និងជា នាយក នាយកដ្ឋាន ទាក់ទងអន្តរជាតិ |
| ៧-ឧត្តមសេនីយ៍ត្រី | នាង | ផែន | អត្តលេខ ០០០៦០១ នាយករង នាយកដ្ឋាន អប់រំ បច្ចុប្បន្នជា នាយក នាយកដ្ឋាន កិច្ចការយោធាស៊ីវិល អគ្គនាយកដ្ឋាន យោធសេវា |
| ៨-ឧត្តមសេនីយ៍ត្រី | គាន់ | ចារណា | អត្តលេខ ០០១៤៥១ នាយករង នាយកដ្ឋាន ផ្គត់ផ្គង់ បច្ចុប្បន្នជា នាយក នាយកដ្ឋាន ផ្គត់ផ្គង់ អគ្គនាយកដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ |
| ៩-ឧត្តមសេនីយ៍ត្រី | ខៅ | សាខន | អត្តលេខ ០០១២០៣ នាយករង នាយកដ្ឋាន នយោបាយផែនការ បច្ចុប្បន្នជា នាយក នាយកដ្ឋាន នយោបាយផែនការ ក្រសួងការពារជាតិ |
| ១០-ឧត្តមសេនីយ៍ត្រី | ហោច | ចំរើន | អត្តលេខ ០០០០៧៦ នាយទាហានរង់ចាំការងារ ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា អគ្គនាយករង អគ្គនាយកដ្ឋាន សំភារៈបច្ចេកទេស ក្រសួងការពារជាតិ |
| ១១-ឧត្តមសេនីយ៍ត្រី | ម៉ែត | និរន្ត្រ | អត្តលេខ ០០០២៣៥ នាយក នាយកដ្ឋាន វិស្វកម្ម បច្ចុប្បន្នជា អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ និងជានាយក នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ |
| ១២-ឧត្តមសេនីយ៍ត្រី | គង់ | អៀង | អត្តលេខ ០០០២៣៩ នាយករង នាយកដ្ឋានវិស្វកម្ម បច្ចុប្បន្នជា មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន |
| ១៣-ឧត្តមសេនីយ៍ត្រី | ឃិន | សុខា | អត្តលេខ ០០១៦២០ នាយករង វិទ្យាស្ថានយោធាកម្ពុជា បច្ចុប្បន្នជា មេបញ្ជាការរង កងទ័ពជើងអាកាស |
| ១៤-ឧត្តមសេនីយ៍ត្រី | ចាប | ម៉ាន់នី | អត្តលេខ ០០០២៨៧ នាយការិយាល័យទី ៥ បច្ចុប្បន្នជា នាយសេនាធិការរង កងទ័ពជើងគោក និងជា នាយការិយាល័យទី ៥ |
| ១៥-ឧត្តមសេនីយ៍ត្រី | អ៊ុច | ម៉ាន់ថា | អត្តលេខ ០០០៤៥១ មេបញ្ជាការ កងវិស្វកម្ម បច្ចុប្បន្នជានាយសេនាធិការរង កងទ័ពជើងគោក និងជា មេបញ្ជាការកងវិស្វកម្ម |

១៦-ឧត្តមសេនីយ៍ត្រី សិរិទ្ធ ហ៊ិន អត្តលេខ ០០០១៦៦ នាយករង នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយសេនាធិការរង កងទ័ពជើងគោក និងជា នាយការិយាល័យទី២

១៧-ឧត្តមសេនីយ៍ត្រី នាង អេង អត្តលេខ ០០០២៤០ នាយក នាយកដ្ឋានអប់រំ បច្ចុប្បន្នជា អគ្គនាយករង អគ្គនាយកដ្ឋាន យោធសេវា និងជា នាយក នាយកដ្ឋានអប់រំ ក្រសួងការពារជាតិ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៤៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ ប្រធានគណៈកម្មការ POW/MIA កម្ពុជា

## សម្រេច

**មាត្រា ១.**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនថ្នាក់ដឹកនាំ និង សមាជិក នៃ គណៈកម្មការ POW/MIA កម្ពុជា ចំនួន ០៨រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ស្រាវជ្រាវជីករុករក អដ្ឋិធាតុ ជនជាតិអាមេរិក និង វៀតណាម ដែលបាត់ខ្លួននៅកម្ពុជា នាសម័យសង្គ្រាម ដូចមានរាយនាមខាងក្រោមនេះ :-

| | | |
|---|---|---|
| ១-ឯកឧត្តម នាយឧត្តមសេនីយ៍ផ្កាយមាស៤ | **ប៊ុល សារឿន** | ប្រធាន |
| ២-ឯកឧត្តម | **សៀង ឡាប្រេស្ស** | អនុប្រធាន |
| ៣-ឯកឧត្តម | **ជ័យ សាផុន** | អនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឌួង ស៊ីផាន** | អនុប្រធាន |
| ៥-លោកវរសេនីយ៍ឯក | **ឌី សូយ៉ាត** | សមាជិកអចិន្ត្រៃយ៍ |
| ៦-លោកឧត្តមសេនីយ៍ត្រី | **គីម ចាន់នី** | សមាជិក |
| ៧-លោកវរសេនីយ៍ឯក | **ខៀវ សាម៉ន** | សមាជិក |
| ៨-លោកវរសេនីយ៍ឯក | **គាំ សុខុន** | សមាជិក |

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការ POW/MIA កម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.05

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤៥. អនក្រ-តត

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

~~~~~

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើ របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ស ំ រ េ ច**

**មាត្រា១.-**

ត្រូវបានតែងតាំងលោក **ឈឹម ឡុង** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការរង នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ
~~~~~

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការ ស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោក **ម៉ៅ វេតនា** ជាជំនួយការស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង

២- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សុជីវ៉ា** ជាជំនួយការស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។-

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៥៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ដូចមានរាយនាម ខាងក្រោម :

១- លោក **ច័ន្ទ មរនា** ជាជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង

២- លោក **ឈឹម មន្តល** ជាជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល ✓
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការ ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម :

១- លោក **ណៃ ម៉េងអ៊ាង** ជាជំនួយការឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោកស្រី **អ៊ាត សោភា** ជាជំនួយការឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅ ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីការរៀបចំសមាសភាពរចនាសម្ព័ន្ធ តួនាទី និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

### សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងមន្ត្រី ០២ រូប ជាជំនួយការផ្ទាល់ឯកឧត្តម **គាត សេខឆ្មា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដូចមានរាយនាមខាងក្រោម :

១- លោក **រំឡូ ធីរៈ** ជាជំនួយការផ្ទាល់ឯកឧត្តម **គាត សេខឆ្មា** ទេសរដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយករង**

២- លោក **ហេង ចិន្តា** ជាជំនួយការផ្ទាល់ឯកឧត្តម **គាត សេខឆ្មា** ទេសរដ្ឋមន្ត្រី មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤៥០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១** : តែងតាំងលោក **អ៊ុន ច័ាល់ឡឺ** ជាប្រធាននាយកដ្ឋាន តាមដាននិងត្រួតពិនិត្យគំរោងនៃគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ២** : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម :

១- លោក **ឈន ជុន** ជាជំនួយការឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង

២- លោក **តឹកអ៊ិត សំរេច** ជាជំនួយការឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៥៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការឯកឧត្តម **ញ៉ឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម :

១- លោក **ម៉ាក់ ឈរា** ជាជំនួយការឯកឧត្តម **ញ៉ឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង

២- លោក **គោង វណ្ណា** ជាជំនួយការឯកឧត្តម **ញ៉ឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការឯកឧត្តម **លូ លាយស្រេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោម :

១- លោក **អៀ រេន** ជាជំនួយការឯកឧត្តម **លូ លាយស្រេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង

២- លោក **សៀក សុផល** ជាជំនួយការឯកឧត្តម **លូ លាយស្រេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.-**

តែងតាំងជាជំនួយការ ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម :

១- លោក **ខៀវ នេន** ជាជំនួយការឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង

២- លោក **អេត ទុន** ជាជំនួយការឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៤៤...សសរ**

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ និងលេខ ៤១ សសរ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ
- យោងឃើញសេចក្តីសំរេចលេខ ១២ សសរ ស្តីពីការបង្កើតក្រុមការងារពិសេសអន្តរក្រសួង_ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៤
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

# សំ រេ ច

**ប្រការ១** : បញ្ចប់អាណត្តិនៃក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលំអបរិស្ថានវិនិយោគ និងសំរួលពាណិជ្ជកម្ម ដែលបានបង្កើតតាមសេចក្តីសំរេចលេខ ១២ សសរ ចុះថ្ងៃទី ២២ ខែមិនា ឆ្នាំ ២០០៤។

**ប្រការ២** : បង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **ជា ចាន់តូ** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- ឯកឧត្តម **ចាន់ សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦- ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧- ឯកឧត្តម **ឡាយ ប្រាហស** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ៨- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

**ប្រការ៣** : គណៈកម្មការដឹកនាំការងារ មានភារកិច្ចដូចតទៅ:

១- ធ្វើជាសេនាធិការឱ្យប្រមុខរាជរដ្ឋាភិបាល ក្នុងការកំណត់ ការដឹកនាំ ការអនុវត្តន៍ និងការតាមដាន សំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណលើចំណុចស្តីពីការអភិវឌ្ឍន៍ផ្នែកឯកជន

២- លើក និងដាក់ឱ្យអនុវត្តនូវវិធានការកែលំអបរិស្ថានវិនិយោគ

៣- លើក និងដាក់ឱ្យអនុវត្តនូវវិធានការសំរបសំរួលពាណិជ្ជកម្ម

៤- លើក និងដាក់ឱ្យអនុវត្តនូវវិធានការជំរុញសហគ្រាសធុនតូច និងមធ្យម

៥- លើក និងដាក់ឱ្យអនុវត្តនូវរាល់វិធានការដទៃទៀត ដើម្បីជំរុញការអភិវឌ្ឍន៍ផ្នែកឯកជន។

**ប្រការ៤** : ភារកិច្ចដូចមានចែងខាងលើនេះ នឹងត្រូវអនុវត្តក្នុងក្របខ័ណ្ឌក្រុមការងារតាមប្រធានបទ។

**ប្រការ៥** : គណៈកម្មការដឹកនាំការងារ ត្រូវរាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីបណ្តាវិធានការនានាដែលបានដាក់ចេញ ។ ក្នុងករណីដែលមានវិធានការលើសសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការដឹកនាំការងារត្រូវរាយការណ៍ សុំការណែនាំ និងការសំរេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៦** : ប្រធានគណៈកម្មការដឹកនាំការងារ អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមការងារបាន ។ ពេលប្រធានអវត្តមាន គណៈកម្មការដឹកនាំការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬ របស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ៧** : ក្នុងករណីចាំបាច់គណៈកម្មការដឹកនាំការងារនេះ អាចសហការជាមួយអ្នកផ្តល់ជំនួយ និង/ឬភាគីពាក់ព័ន្ធមកពីផ្នែកឯកជន ដើម្បីសំរេចបានប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចខាងលើ ។

**ប្រការ៨** : គណៈកម្មការដឹកនាំការងារ នេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ នឹងសហាសភាពដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៩*
- *ឯកសារ.កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..០២..សរណន

# សារាចរណែនាំ

# ស្តីពី

# ការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក

កន្លងមកក្រសួង ស្ថាប័នបានធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅតាមមុខតំណែង និងតាំបៀវត្សចាស់ ដោយផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌថ្មីតាមខ្លឹមសារនៃអនុក្រឹត្យ លេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ។ ទន្ទឹមនឹងនេះ ក្រសួងស្ថាប័នមួយចំនួនក៏បានធ្វើការតែងតាំងមន្ត្រីអោយចូលក្នុងក្របខ័ណ្ឌថ្មីដែរ ប៉ុន្តែពុំទាន់បានចប់សព្វគ្រប់តាមចំនួនក្របខ័ណ្ឌដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែកនីមួយៗ និងស្របតាមទិសដៅកំណែទំរង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល។ ចំពោះមុខ ដើម្បីជំរុញការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែកនីមួយៗអោយបានឆាប់រហ័ស រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចខាងក្រោម :

១- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៅក្រោមឱវាទដោយកំណត់ឱ្យបានច្បាស់លាស់នូវមន្ត្រីដែលត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលទូទៅ ក្របខ័ណ្ឌក្រសួងមហាផ្ទៃផ្នែករដ្ឋបាល-ស៊ីវិល ក្របខ័ណ្ឌមន្ត្រីការទូត ក្របខ័ណ្ឌគ្រូបង្រៀន ក្របខ័ណ្ឌមន្ត្រីសុខាភិបាល ក្របខ័ណ្ឌបច្ចេកទេសទៅតាមប្រភេទ **ក** **ខ** **គ** និង **ឃ** ដែលបានបង្កើតតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក។

២- ចំពោះប្រភេទក្របខ័ណ្ឌនីមួយៗ ក្រសួង ស្ថាប័នត្រូវកំណត់អោយបានច្បាស់លាស់នូវមន្ត្រីដែលស្ថិតនៅក្នុងឋានន្តរស័ក្តិ ទី១ ឋានន្តរស័ក្តិទី២ និងឋានន្តរស័ក្តិ ទី៣ ទៅតាមសមាមាត្រគិតអតិបរមា ៥ភាគរយ ក្នុងឋានន្តរសក្តិទី១ និង ២៥ភាគរយ ក្នុងឋានន្តរស័ក្តិទី២ ដោយធ្វើការប្រៀបធៀបទៅនឹងចំនួនមន្ត្រីសរុបនៅក្នុងប្រភេទក្របខណ្ឌ័នីមួយៗ។

៣- ដើម្បីបំពេញសមាមាត្រក្នុងឋានន្តរស័ក្តិទី១ និង ទី២ ក្រសួង ស្ថាប័ន ត្រូវធ្វើការវាយតម្លៃអោយបានម៉ត់ចត់បំផុត ដោយផ្អែកលើលក្ខណៈសម្បត្តិ និងមុខតំណែងដែលទទួលខុសត្រូវរបស់មន្ត្រីរាជការនៃ

ក្របខ័ណ្ឌនីមួយៗ ដោយប្រើប្រាស់ឯកសារដែលក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានបោះពុម្ពធ្វើជាមូលដ្ឋាន ក្នុងការពិនិត្យ និងវាយតម្លៃ និងតាមនីតិវិធីផ្ទៃក្នុងនីមួយៗ។

៤- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្ដីពីការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ហើយបញ្ជូនទៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីធ្វើសុពលភាព ដោយមានការចូលរួមពីតំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីក្រសួង ស្ថាប័ន។

៥- ការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាស អោយបានចប់ជាស្ថាពរនៅមុនដំណាច់ខែ មេសា ឆ្នាំ ២០០៤។ ដោយឡែកចំពោះក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើឱ្យបានចប់នៅត្រីមាសទី៣ នៃឆ្នាំ ២០០៤ ។

ទទួលបានសារាចរណែនាំនេះក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការ និងចាត់តាំងអនុវត្តអោយឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលល្អប្រសើរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦. ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្ដីជម្រាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ០៣ សរណន**

# សារាចរណែនាំ

## ស្តីពី

## ការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការទប់ស្កាត់ និងការបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨ ត្រូវនឹងថ្ងៃទី ១៣ ទី ១៤ និងទី ១៥ ខែ មេសា ឆ្នាំ ២០០៤

បន្ទាប់ពីការអនុវត្តនយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលមក ព្រះរាជាណាចក្រកម្ពុជា បានទទួលនូវសន្តិភាពពេញលេញទូទាំងប្រទេស ប្រជាពលរដ្ឋខ្មែរមានឱកាសធ្វើដំណើរទៅមក ដើម្បីធ្វើអាជីវកម្មនានា សួរសុខទុក្ខគ្រួសារ ជួបជុំញាតិមិត្ត ជាពិសេសការប្រារព្ធពិធីលេងល្បែង របាំប្រជាប្រិយ និងការរាំកំសាន្ត ស្របតាមទំនៀមទំលាប់ជាតិខ្មែរ យ៉ាងសប្បាយរីករាយក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិម្តងៗ ។

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ ០៩ សរណន ចុះថ្ងៃ ទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ដើម្បីប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងខេត្ត-ក្រុង អនុវត្តជាអចិន្ត្រៃយ៍ ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ រួចហើយ ។ ប៉ុន្តែនៅពេលកន្លងមកថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា បាតុភាពលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ បានកកើតឡើងតាមមូលដ្ឋាន និងតំបន់មួយចំនួននៃខេត្ត-ក្រុង បណ្តាលអោយកើតមានជាបទល្មើសឧក្រិដ្ឋផ្សេងៗ គួរអោយកត់សំគាល់ ។

ដើម្បីថែរក្សា ការពារវប្បធម៌ ប្រពៃណីជាតិដ៏រុងរឿងពីបុរាណរបស់ខ្មែរ និងធានាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ទប់ស្កាត់ និងបង្ក្រាបការលេងល្បែងស៊ីសងខុសច្បាប់គ្រប់

ប្រភេទនៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨ ត្រូវនឹងថ្ងៃទី ១៣ ទី ១៤ និងទី ១៥ ខែ មេសា ឆ្នាំ ២០០៤ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ ÷

១-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងទេសចរណ៍ និង គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវធ្វើការណែនាំដល់មន្ទីរ អង្គភាពជំនាញ ក្រោមឱវាទ របស់ខ្លួន និងប្រជាពលរដ្ឋទូទាំងប្រទេស អោយរៀបចំតុបតែងលំអលំនៅដ្ឋាន ទីក្រុង ទីប្រជុំជន ទីសាធារណៈ វត្តអារាម និងរមណីយដ្ឋាននានា ចាត់តាំងពិធីគោរពវិញ្ញាណក្ខន្ធរបស់បុព្វបុរស ជីដូនជីតា ញាតិសន្តាន ដែលបានធ្វើមរណកាលកន្លងទៅ ការលេងល្បែង របាំប្រជាប្រិយ និងការរាំកំសាន្ត ស្របតាម ប្រពៃណីជាតិខ្មែរពីបុរាណនៅតាមទីវត្តអារាម រមណីយដ្ឋាននានា និងតាមមូលដ្ឋានភូមិ ឃុំ និងសង្កាត់ របស់ខ្លួន អោយបានសប្បាយរីករាយ ។

២-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គបញ្ជាការដ្ឋានកង យោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ត្រូវធ្វើការណែនាំដល់គ្រប់ខេត្ត ក្រុង តាមជំនាញរៀងៗខ្លួន ដើម្បីមានវិធានការម៉ឺងម៉ាត់ ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ធានាទប់ស្កាត់ អំពើលួច ឆក់ ប្លន់ និងអំពើល្មើសច្បាប់ផ្សេងៗទៀត ជាពិសេសការទប់ស្កាត់ និងបង្ក្រាបរាល់ការលេងល្បែង ស៊ីសងខុសច្បាប់គ្រប់ប្រភេទ ដែលជាមូលហេតុចម្បងបង្កអោយ មានអំពើឧក្រិដ្ឋ និងបទល្មើសព្រហ្មទណ្ឌ នានា ក្នុងឱកាសដែលប្រជាពលរដ្ឋទូទាំងប្រទេស ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ខាងមុខនេះ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងទេសចរណ៍ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវធ្វើការផ្សព្វផ្សាយ និងធ្វើការណែនាំលំអិតបន្ថែមទៀត ដើម្បីអនុវត្តតាម ខ្លឹមសារខាងលើ ដល់កំលាំងមានសមត្ថកិច្ច និងមន្ត្រីក្រោមឱវាទ អោយទទួលអនុវត្តប្រកបដោយ ប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៤ សរណន

# សារាចរណែនាំ
# ស្តីពី
# ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១១៨
# ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ឆ្នាំ ២០០៤

ទិវាពលកម្មអន្តរជាតិ ១ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលចាប់ផ្តើមឡើងនាឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើអោយប្រសើរនូវស្ថានភាពនៃលក្ខខណ្ឌការងារ និង ជីវភាពរស់នៅរបស់ប្រជាពលករ។ នៅកម្ពុជា ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ តាំងពីក្រោយថ្ងៃ ០៧ មករា ១៩៧៩ ហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលក៏បានកំណត់យកថ្ងៃ ០១ ឧសភា គឺជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សំរាករបស់កម្មករ និយោជិត។ បណ្តាស្ថាប័នរដ្ឋ កម្មករ និយោជិតនៃរោងចក្រ សហគ្រាស ជាច្រើនបានរៀបចំទិវានេះ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព។

ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងអនុវត្តលក្ខខណ្ឌការងារ ធានាសិទ្ធិ ផលប្រយោជន៍កម្មករនិយោជិតតាមច្បាប់ស្តីពីការងារ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន១២ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន៧។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ត្រូវបានបង្កើតក្នុងគោលបំណងធ្វើអោយលក្ខខណ្ឌការងារ និងជីវភាពរបស់កម្មករ និយោជិត កាន់តែប្រសើរឡើង។ ទន្ទឹមនឹងការពង្រឹងការអនុវត្តន៍ច្បាប់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា យើងបានបន្តអនុវត្តគំរោងឃ្លាំមើលលក្ខខណ្ឌការងារឯករាជ្យ ដែលចាត់ចែងដោយអង្គការអន្តរជាតិខាងការងារ (ILO)។ លក្ខខណ្ឌការងារនៅកម្ពុជាមានការអភិវឌ្ឍន៍ល្អ ជាពិសេសពុំមានការងារដោយបង្ខំ ភាពរើសអើង និងពលកម្មកុមារ គួរឱ្យកត់សំគាល់ឡើយ។ សិទ្ធិសហជីព សិទ្ធិកូដកម្ម ឡុកអៅ ត្រូវបានអនុវត្តយ៉ាងពេញលេញ។ គណៈកម្មការប្រឹក្សាការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាយន្តការត្រីភាគី ត្រូវបានរៀបចំអនុវត្តតួនាទីភារកិច្ចយ៉ាងសកម្ម តាមការកំណត់នៃច្បាប់ និងធានាបាននូវភាពជាដៃគូរ របស់គ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យការងារ។

វិស័យការងារកម្ពុជា បាននិងកំពុងជាកំលាំងជំរុញថ្មីមួយនៃការប្រកួតប្រជែង និងពង្រីកទីផ្សារ នាំចេញផលិត

ផលទៅ អាមេរិក អឺរ៉ុប និងប្រទេសដទៃទៀត ដែលបានបង្កើតការងារថ្មីជាច្រើនកន្លែង ។

ដើម្បីអោយការប្រារព្ធទិវាពលកម្មអន្តរជាតិ ០១ ឧសភា ខួបលើកទី ១១៨ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចខាងក្រោមនេះ :

១-ក្រសួងពត៌មាន ម៉ាស៊ីនឃោសនារបស់រដ្ឋត្រូវផ្សព្វផ្សាយ អោយសង្គមជាតិទាំងមូល យល់ពីអត្ថន័យទិវាពលកម្មអន្តរជាតិ ០១ ឧសភា គឺជាសមិទ្ធិផលរបស់មនុស្សជាតិ ដែលបានបង្កើតនូវលក្ខខណ្ឌការងារជាស្តង់ដា សំរាប់ការអនុវត្តន៍សព្វថ្ងៃនេះ ជាអាទិ៍ពាក្យស្លោក ៨ ម៉ោងធ្វើការ ៨ ម៉ោងសំរាក ៨ ម៉ោងរៀនសូត្រ ជាដើម ។

២-ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវណែនាំសហគ្រាស គ្រឹះស្ថាន សហការគ្នារៀបចំទិវា ០១ ឧសភា តាមរូបភាពដូចជា :

-រៀបចំចាត់តាំងការជួបជុំសំណេះសំណាលតាមសហគ្រាស គ្រឹះស្ថាន ទទួលអំណរទិវា ០១ ឧសភា

-ចាត់តាំងការជួបជុំជប់លៀង កំសាន្តសប្បាយ ការដើរកំសាន្ត គ្រប់រូបភាពតាមលទ្ធភាពរៀងៗខ្លួន ដើម្បីបង្កបរិយាកាសសាមគ្គីភាព ភាតរភាព នៅតាមសហគ្រាស គ្រឹះស្ថាន ។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរខេត្ត-ក្រុង និងស្ថាប័ន ពាក់ព័ន្ធទាំងអស់ ត្រូវតែមានការណែនាំសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងបង្កលក្ខណៈងាយស្រួលដល់សហគ្រាស គ្រឹះស្ថាន ដែលបោះទីតាំងក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងឱកាសទិវាបុណ្យ ០១ ឧសភា ឆ្នាំ ២០០៤ នេះ ។

រាជរដ្ឋាភិបាលសូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ ចូលរួមអបអរទិវា ០១ ឧសភា ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព ភាតរភាព ដើម្បីការអភិវឌ្ឍន៍នៃប្រទេសជាតិយើង ។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត ក្រុង រៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង
"ដើម្បីសហការអនុវត្ត"
-ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៥ ស.ស.ណ.ន

## សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី៥៥ " ទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា "

នៅក្នុងអំឡុងឆ្នាំ១៩៤២-៤៤ ពួកហ្វាស៊ីស្តអ៊ីត្លែបានបង្កអំពើវិនាសកម្មដ៏សែនរន្ធត់ ដោយបានកាប់សម្លាប់ស្ត្រី និងកុមារ នៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរ៉ាឌូប្រទេសបារាំង ។ វិនាសកម្មនេះបានបង្កើតនូវកំហឹងឈឺចាប់លើពិភពលោក ហើយសម័យប្រជុំសម្ព័ន្ធនារីអន្តរជាតិ នាឆ្នាំ១៩៤៩ បានឯកភាពកំណត់យកថ្ងៃ ១ មិថុនា រៀងរាល់ឆ្នាំជា "ទិវាកុមារអន្តរជាតិ" ។

នៅថ្ងៃ២០ វិច្ឆិកា ១៩៨៩ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ គោលដៅសកលលោកដើម្បីកុមារ ក៏ត្រូវបានអនុម័តដោយសន្និសីទកំពូលពិភពលោកដើម្បីកុមារនាឆ្នាំ១៩៩០ ។ សម័យប្រជុំពិសេសស្តីពីកុមារនៃអង្គការសហប្រជាជាតិ នៅខែឧសភា ឆ្នាំ២០០២ និងលទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីកុមារប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ឆ្នាំ២០០៣ នៅកោះបាលី បានកំណត់បញ្ហាអាទិភាព៤របស់កុមារគឺ : មរណៈភាពមាតា អាហារូបត្ថម្ភ មេរោគអេដស៍/ជម្ងឺអេដស៍ និងកិច្ចការពារ ។

ដោយឡែកនៅប្រទេសកម្ពុជា មហាវិនាសកម្មដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុលពត បានធ្វើអោយប្រជាជន យុវជន កុមារ ក្លាយជាទាសករ រស់នៅយ៉ាងសែនវេទនា រងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌រាប់លាននាក់ ។ ការងារកុមារ ត្រូវបានយកចិត្តទុកដាក់ ពិសេសចាប់តាំងពីក្រោយថ្ងៃ៧ មករា ១៩៧៩មក ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាបានលើកស្ទួយដល់សិទ្ធិទាំង៤របស់កុមារ ។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរគឺ : ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ ។

ដើម្បីបង្កើនកិច្ចគាំទ្រដល់កុមារកម្ពុជា ដែលជាអ្នកបន្តវេនប្រទេសជាតិឱ្យទទួលបាននូវសិទ្ធិកាន់តែល្អប្រសើរថែមទៀតនោះ ក្នុងឱកាសទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០០៤ ខាងមុខនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅៈ

១- ក្រសួង ស្ថាប័ន និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ត្រូវផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និង សង្គមជាតិទាំងមូល បានជ្រួតជ្រាបអំពីប្រវត្តិទិវាកុមារអន្តរជាតិ និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា អនុសញ្ញា ឬ សេចក្តីប្រកាស អន្តរជាតិនានាដែលពាក់ពន្ធ័នឹងកុមារ និងរៀបចំកម្មវិធីជួបជុំសំណេះសំណាល និងមានការចាត់តាំងកំសាន្ត សប្បាយរបស់កុមារនៅក្នុងមូលដ្ឋានរបស់ខ្លួនទៅតាមលទ្ធភាពជាក់ស្តែង ។

២- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមិទ្ទិញព្យុះហយាត្រាកុមារ និង កម្មវិធីកំសាន្តផ្សេងៗសំរាប់កុមារ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៤ ឱ្យបាន ឱឡារិកអធិកអធមនៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ។

៣- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាសំរាប់ការរៀបចំពិធីនេះ ។

៤- រាជរដ្ឋាភិបាលសូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រ ដល់កម្មវិធីនេះអោយបានផុសផុល និងអធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីសហការអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦. សរណន

# សារាចរណែនាំ
## ស្តីពី
## ការទប់ស្កាត់ និងលុបបំបាត់ការលួចបន្លំ ស្បៀងពលកម្មរបស់អង្គការស្បៀងអាហារពិភពលោក

កន្លងមករាជរដ្ឋាភិបាលបានកត់សំគាល់ឃើញថា អង្គការស្បៀងអាហារពិភពលោក WFP និង សហគមន៍អន្តរជាតិ បានអនុវត្តគំរោងក្នុងការផ្តល់ជំនួយស្បៀងពលកម្មដល់ប្រជាពលរដ្ឋ ដែលខ្វះខាតស្បៀងអាហារនៅទូទាំងប្រទេស តាមរយៈការស្តារ និងស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាអាទិ៍: កសាងផ្លូវលំ ជីកស្រះ និងស្តារប្រព័ន្ធធារាសាស្ត្រ ខ្នាតតូច និងមធ្យម សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និង ការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋនៅទីជនបទ ។

ប៉ុន្តែ ទន្ទឹមនឹងការប្រើប្រាស់ជំនួយរបស់អង្គការស្បៀងអាហារពិភពលោក ដែលទទួលបានលទ្ធផលគួរជាទីមោទនៈនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញមាន បាតុភាពអសកម្មកើតឡើងគួរឱ្យព្រួយបារម្ភ ចំពោះសាធារណមតិជាតិ និងអន្តរជាតិ ដែលក្នុងនោះបាតុភាពលេចធ្លោ មានការឃុបឃិតគ្នាលួចបន្លំយកស្បៀងពលកម្ម ដែលជាជំនួយមនុស្សធម៌របស់អង្គការស្បៀងអាហារពិភពលោក និងសហគមន៍អន្តរជាតិ ក្រោមរូបភាពលួចបំប៉ោងបរិមាណទំហំផ្ទៃក្រឡា និងចំនួនពលករ ដែលបានចូលរួមស្តារហេដ្ឋារចនាសម្ព័ន្ធនីមួយៗ ឬក្រោមរូបភាពផ្សេងៗទៀត ដើម្បីយកទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មន្ត្រី និងជនខិលខូចមួយចំនួន ។

ដើម្បីដោះស្រាយនូវបាតុភាពអសកម្មខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការចាំបាច់ចំពោះមុខជាបន្ទាន់ និងសូមធ្វើការណែនាំដូចតទៅ :

១-អង្គភាពប្រឆាំងអំពើពុករលួយ នៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវសហការជាមួយអង្គការស្បៀងអាហារពិភពលោក និងអាជ្ញាធរដែនដី ដើម្បីចុះស្រាវជ្រាវអោយបានហ្មត់ចត់ និងរកឱ្យឃើញនូវជនល្មើស ក្នុងការលួចបន្លំស្បៀងពលកម្ម ដែលជាជំនួយមនុស្សធម៌របស់កម្មវិធីស្បៀងអាហារពិភពលោក សំរាប់ចែកជូនប្រជាពលរដ្ឋក្នុងការធ្វើពលកម្ម កសាង ហេដ្ឋារចនាសម្ព័ន្ធ ដូចជាស្ថាបនាផ្លូវលំ ជីកស្រះ លើកទំនប់ប្រព័ន្ធធារាសាស្ត្រតូច និងមធ្យម និងឧបត្ថម្ភដល់ សិស្សានុសិស្ស និងជនក្រីក្រងាយរងគ្រោះ នៅតាមមូលដ្ឋាន ភូមិ ឃុំ សាលារៀន មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកតាមស្រុក ខណ្ឌ ដើម្បីមានវិធានការតាមច្បាប់ជាធរមាន ។

ចំពោះមន្ត្រីរាជការណាដែលបានប្រព្រឹត្តបទល្មើសលួចបន្លំស្បៀងពលកម្ម និង ស្បៀងជាជំនួយឧបត្ថម្ភរបស់អង្គការស្បៀងអាហារពិភពលោក និងសហគមន៍អន្តរជាតិ ដើម្បីបំរើឱ្យផលប្រយោជន៍បក្សពួកផ្ទាល់ខ្លួន ក្រសួង ស្ថាប័នសាមីនីមួយៗ ត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល និងត្រូវមានវិធានការរដ្ឋបាល និងសងសំណងនូវការបាត់បង់ស្បៀងជូនរដ្ឋវិញ ហើយក្នុងករណីធ្ងន់ធ្ងរ ត្រូវកសាងសំណុំរឿងបញ្ជូនជនល្មើសទៅតុលាការ ដើម្បីធ្វើការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។

២-ក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អំពីការធ្វើសំណើសុំស្បៀងពលកម្ម ឬជំនួយឧបត្ថម្ភជូនប្រជាពលរដ្ឋក្រីក្រ ខ្វះខាតស្បៀង និងជនងាយរងគ្រោះ ចាស់ជរា គ្មានទីពឹង ធ្វើគំរោងឱ្យបានរលូន ស្មោះត្រង់ និងពិតប្រាកដ ចៀសវាងការលួចបំប៉ោងតួលេខ ផ្ទៃក្រឡា ឬចំនួនពលករ ដោយធ្វើសំណើសុំស្បៀងលើសពីចំនួនពិត ដែលត្រូវការជាក់ស្តែងសំរាប់ចែកឱ្យអ្នកធ្វើពលកម្ម ឬចំនួនសិស្សានុសិស្ស អ្នកជំងឺ និងជនក្រីក្រផ្សេងទៀត ដោយខិតខំចៀសវាងនូវការលាក់បន្លំ ព្រមទាំងចែកចាយស្បៀងដែលលើសទៅឱ្យអ្នកផ្សេងទៀត ខុសពីគោលដៅ ។

៣-ក្រសួងអភិវឌ្ឍជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវធ្វើការអប់រំ និងណែនាំដល់មន្ត្រីរាជការក្រោមឱវាទដែល ទទួលការងារអនុវត្តគំរោងពាក់ព័ន្ធនឹងការទទួលប្រើប្រាស់ស្បៀងពលកម្ម និង ជំនួយឧបត្ថម្ភដល់សិស្សានុសិស្ស ប្រជាពលរដ្ឋក្រីក្រខ្វះខាតស្បៀង ឱ្យបង្កើននូវស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានានូវការជឿទុកចិត្តពីអង្គការស្បៀងអាហារពិភពលោក និងសហគមន៍អន្តរជាតិ ចំពោះរាជរដ្ឋាភិបាល ក្នុងការបន្តផ្តល់ជំនួយស្បៀងពលកម្ម ដើម្បីជួយឧបត្ថមឱ្យបានដល់ដៃប្រជាពលរដ្ឋក្រីក្រពិតប្រាកដតទៅទៀត ។

៤-ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដី ត្រូវបង្កើនកិច្ចសហការជាមួយអង្គការស្បៀងអាហារពិភពលោក និងតំណាងបណ្តាប្រទេសជាម្ចាស់ជំនួយឱ្យបានល្អ ដើម្បីកសាងភាពជាដៃគូ ក្នុងការទទួល និងផ្តល់ជំនួយស្បៀងឱ្យបានកាន់តែច្រើនថែមទៀត ជូនដល់ដៃសិស្សានុសិស្ស ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

៥-ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់កម្មវិធីជាកំណត់ក្នុងការជួបប្រជុំគ្នា ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ អំពីកម្មវិធីស្បៀងអាហារនេះឱ្យបានញឹកញាប់ ជាមួយអង្គការស្បៀងអាហារពិភពលោក អង្គការអន្តរជាតិ និងប្រទេសផ្តល់ជំនួយ ដើម្បីពិភាក្សាអំពីការកំណត់រៀបចំឡើងវិញនូវគោលការណ៍រួម និងរចនាសម្ព័ន្ធស្តីពី ការគ្រប់គ្រង និង ការប្រើប្រាស់ស្បៀងពលកម្ម របស់អង្គការស្បៀងអាហារពិភពលោក សំដៅឱ្យការប្រើប្រាស់ជំនួយនេះបានសមស្រប និងចំគោលដៅ និងធានាមិនឱ្យមានការបាត់បង់ស្បៀងដូចរយៈពេលកន្លងមក។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី ត្រូវធ្វើការផ្សព្វផ្សាយអប់រំជូនដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ឱ្យបានយល់ជ្រួតជ្រាប និងទទួលអនុវត្តឱ្យបានសំរេចលទ្ធផលជាវិជ្ជមាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-សាលាខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ៧១៨ សហវ.ប្រក

ភ្នំពេញ ថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*********

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ០៩ សជណ.អត របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា
- ផ្អែកលើភាពចាំបាច់នៃការងារកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## សម្រេច

***

**ប្រការ ១:** បង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហៅកាត់ **គកហ** ដែលរួមមានសមាសភាពដូចខាងក្រោម ÷

### *I. ថ្នាក់ដឹកនាំ កសហវ*

| | | |
|---|---|---|
| ១- ឯកឧត្តម **គួន ព័ន្ធមុនីរ័ត្ន** | រដ្ឋលេខាធិការ កសហវ | ប្រធាន |

### *II. ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន កសហវ*

| | | |
|---|---|---|
| ២- ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការ កសហវ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **ជុំ គឹមឡេង** | អគ្គលេខាធិការរង កសហវ | អនុប្រធាន |
| ៤- ឯកឧត្តម **ចន្ទ្រី ចិន្ដសុត** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៥- ឯកឧត្តម **ជុំ ទិជីគ្ត** | អគ្គលេខាធិការរង កសហវ | សមាជិក |
| ៦- ឯកឧត្តម **ហ៊ាង សារ៉ុម** | អគ្គលេខាធិការរង កសហវ | សមាជិក |

### *III. ថ្នាក់ដឹកនាំនាយកដ្ឋាន កសហវ*

| | | |
|---|---|---|
| ៧- ឯកឧត្តម **រ៉ម៉ែន ស៊ីម៉ែន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៨- ឯកឧត្តម **ទិន ឃុន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ | សមាជិក |
| ៩- លោក **នួច ឡេង** | ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច | សមាជិក |
| ១០- លោក **ហុង ថា** | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ១១- លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ | សមាជិក |
| ១២- លោក **គាំង សារ៉េខ័ណ្ឌ** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៣- លោក **ឆាយ ឌុន** | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៤- លោក **ជា ឌុនណារ** | ប្រធាននាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច | សមាជិក |
| ១៥- លោក **លឹម ម៉ុនសែ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |

១៦- លោក ម៉ម និច អគ្គាធិការនៃអគ្គាធិការដ្ឋាន សមាជិក

១៧- លោក សេង ស្រេង នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១៨- លោក មោគ សុធារិន ប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

១៩- លោក យិនឌី តំយឈន់ ប្រធាននាយកដ្ឋាននីតិកម្ម សមាជិក

២០- លោក មុី ទ៉ាន់ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សមាជិក

២១- លោក ទ៊ុយ សម្បត្តិ ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច
និង អាស៊ាន សមាជិក

២២- លោក ឃុត សារ៉េន ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ សមាជិក ។

**ប្រការ ២:** គណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានមុខងារ និង ភារកិច្ច ដូចតទៅ ÷

- ធ្វើជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំ និង តាម-ដានការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រសួង នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលការងារនេះ ជាមួយនឹងទីស្តីការគណៈរដ្ឋមន្ត្រី ។
- ធ្វើជាលេខាធិការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំនូវចក្ខុវិស័យ កម្មវិធី និង ផែនការសកម្មភាពនានា សំដៅកែលម្អ និង ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របទៅតាមតម្រូវការនៃការ-អភិវឌ្ឍន៍ប្រទេស និង ស្របតាមស្តង់ដារនៃការអនុវត្តន៍នៅក្នុងតំបន់ និងជាអន្តរជាតិ ។
- ដឹកនាំ និង តាមដានការអនុវត្តចក្ខុវិស័យ កម្មវិធី និង ផែនការសកម្មភាព សម្រាប់កែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធានាឱ្យបាននូវសង្គតិភាព លំដាប់លំដោយត្រឹមត្រូវ និងប្រសិទ្ធភាពខ្ពស់នៅក្នុងកិច្ចដំណើរការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង រវាងកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងកំណែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល ។
- ធ្វើជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការសម្របសម្រួលកិច្ចការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងក្រសួង និង ស្ថាប័ននានា នៃរាជរដ្ឋាភិបាល រួមទាំងខេត្ត-ក្រុង នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីវិសហមជ្ឈការ និង វិមជ្ឈការផង ។

- ធ្វើជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកៀងគរជំនួយ និង ក្នុងការសំរបសំរួលការអនុវត្តន៍កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយ នឹងដៃគូអ្នកផ្តល់ជំនួយនានា ។

**ប្រការ ៣:** «**គគហ**» ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងមួយខែមួយដង តាមការអញ្ជើញរបស់ប្រធាន ឬ អាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

**ប្រការ ៤:** «**គគហ**» អាចបង្កើតគណៈកម្មការ ឬ ក្រុមការងារផ្សេងៗ ទៅតាមតម្រូវការចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង កម្មវិធីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ ៥:** ប្រធាន «**គគហ**» អាចអញ្ជើញថ្នាក់ដឹកនាំ និង មន្ត្រីជំនាញនានា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមិនមែនជាសមាជិកនៃ «**គគហ**» ឱ្យចូលរួមប្រជុំទៅ តាមតម្រូវការ ចាំបាច់នៃការងារ ។

**ប្រការ ៦:** ក្នុងករណីអវត្តមាន សមាជិកនៃ «**គគហ**» ដែលជាប្រធាននាយកដ្ឋាន អាចស្នើសុំការ-អនុញ្ញាតពីប្រធាន «**គគហ**» ដើម្បីចាត់តាំងអនុប្រធាននាយកដ្ឋានមួយរូប ឱ្យចូលរួម ប្រជុំជំនួស ។ សមាជិក «**គគហ**» អាចស្នើសុំការអនុញ្ញាតពីប្រធាន «**គគហ**» ឱ្យមន្ត្រី ជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារកែទម្រង់នៅក្នុងអង្គភាពរបស់ខ្លួន ចូល រួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ ។

**ប្រការ ៧:** «**គគហ**» មានលេខាធិការដ្ឋានមួយ ជាសេនាធិការបច្ចេកទេសរបស់ខ្លួន ក្នុងការបំពេញ ការងារ ។ សមាសភាព មុខងារ និងភារកិច្ចលម្អិត របស់លេខាធិការដ្ឋាន «**គគហ**» នឹង ត្រូវបានកំណត់នៅក្នុងល័ក្ខខ័ណ្ឌយោងដោយឡែក ដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន «**គគហ**» ។

**ប្រការ ៨:** «គគមា» ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន ។

**ប្រការ ៩:** រាល់ប្រកាស និង លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ព្រមទាំងប្រកាសលេខ ០៨១ សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៤ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០:** ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

__ចម្លងជូន:__
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង- ស្ថាប័ន និង ខេត្ត- ក្រុង
- គ្រប់ថ្នាក់ដឹកនាំនៃ គសហវ
- គ្រប់នាយកដ្ឋានក្រោមឱវាទ គសហវ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ២៧០ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារសំរាប់ប្រមូលចំណូលមិនមែនសារពើពន្ធ ក្រៅពីទ្រព្យរដ្ឋ និងឧស្សាហកម្មហិរញ្ញវត្ថុ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** បង្កើតក្រុមការងារ Ad-Hoc សំរាប់ប្រមូលចំណូលមិនមែនសារពើពន្ធ ក្រៅពីទ្រព្យរដ្ឋ និងឧស្សាហកម្មហិរញ្ញវត្ថុ ទាំងនៅរដ្ឋបាលកណ្តាល ទាំងនៅតាមខេត្ត-ក្រុង ដែលមានសមាសភាពដូចតទៅ:

១- ឯកឧត្តម អ៊ុំ ម៉ិនឡុង រដ្ឋលេខាធិការ ប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តម ទី តាយី | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- លោក ជា ទ៊ិន | ប្រធានការិ. គ្រប់គ្រងការងារហិរញ្ញកិច្ចនៃនាយកដ្ឋាន ថវិកានីយកម្ម និងហិរញ្ញកិច្ច | លេខាធិការ |
| ៤- លោក ចាន់ ស៊ុំ | អនុប្រធានពន្ធដារ | សមាជិក |
| ៥- លោក ម៉ឺន មុណ្ណារិទ្ធ | អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៦- លោកស្រី ស៊ីទ គីមស៊ាន | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៧- លោក ម៉ុ ចន្ទសុខា | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ៨- លោកស្រី ស៊ីន ម៉ូលីចណ្ណា | ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៩- លោក ឡុញ ម៉ុន្ណារ៉ា | ប្រធានការិ. អធិការកិច្ចខេត្ត- ក្រុងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ១០- លោក ចាន់ ហឿន | អនុប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អមរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | សមាជិក |

**ប្រការ២:** ក្រុមការងារ មានសិទ្ធិអញ្ជើញមន្ត្រីពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមផ្តល់យោបល់ ក្នុងករណីចាំបាច់ ។

**ប្រការ៣:** ក្រុមការងារនេះ ត្រូវរៀបចំផែនការ និងអនុវត្តសកម្មភាពការងារ ប្រមូលចំណូល ទារបំណុល ព្រមទាំងវិធានការតឹងទារចំពោះគោលដៅដូចខាងលើ ។

**ប្រការ៤:** ក្រុមការងារ Ad-Hoc ត្រូវធ្វើរបាយការណ៍ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រចាំអំពីលទ្ធផល ដែលខ្លួនសំរេចបានក្នុងការបំពេញភារកិច្ចខាងលើ ហើយ ជាយថាហេតុសុំការណែនាំ និងវិធានការសំរាប់កិច្ចការនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៥:** ឯកឧត្តម និងអស់លោក ដែលមានរាយនាមក្នុងប្រការ១ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ គ្រប់នាយកដ្ឋាន និងអង្គភាព ពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៤

**គាត ឈន់**

**កន្លែងទទួល:**

- គ្រប់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. 144 MOC / M 2004

ភ្នំពេញ.ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីលទ្ធផល នៃការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ និងការបន្តសុពលភាពនៃកិច្ចព្រមព្រៀងនេះ តាមអនុស្សារណៈនៃការយោគយល់គ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១ ។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ១៤១ MOC / M 2004 ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ ដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៤ ។
- យោងតាមការចាំបាច់នៃការងារ ។

## សំរេច

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់និមួយ ៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៤ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានគាំពារត្រួតពិនិត្យ ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រោងចក្រផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចំលងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

  " ដើម្បីជ្រាបជាព័ត៌មាន "
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 , 821223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. 144 MOC / M 2004

*From the Minister's Desk*

Phnom Penh, July 28, 2004

# PRAKAS

## On the result of Tender for the Quota on Garments to be exported to the United States of America in FY 2004

***THE MINISTER OF COMMERCE***

- Pursuant to the constitution of the Kingdom of Cambodia;
- Pursuant to the Royal Decree No. 02/NS/94 dated July 20, 1994 on the Organisation and Functioning of the Council of Ministers;
- Pursuant to the Royal Decree No. NS/RKT/0704/124 dated July 15, 2004 on the appointment of the Royal Government of Cambodia;
- Pursuant to the Royal Decree No.0196/16 dated January 24, 1996 on the establishment of the Ministry of Commerce;
- Pursuant to Sub-Decree No. 54 AK dated September 22, 1997 on the organisation and functioning of the Ministry of Commerce.
- Pursuant to the Agreement relating to Trade in Cotton, Wool, Man-made Fiber, Non-Cotton Vegetable Fiber and Silk Blend Textiles and Textiles Product between the Royal Government of Cambodia and the Government of the United States of America dated January 20, 1999, and its extension by the Memorandum of Understanding signed between the Royal Government of Cambodia and the Government of the United States of America on December 31, 2001;
- Pursuant to the meeting of the Council Ministers dated January 29, 1999.
- Pursuant to the Prakas of the Ministry of Commerce No.017 MoC/M2004 dated February 10, 2004, on the Tender Bid for the Quota on garments to be exported to the United States of America in FY 2004.
- Having seen the needs of the Ministry.

***DECIDES***

**Article 1**: Acknowledge the result of tender for Quota of individual garment category to be exported to the United States of America in the FY 2004, which is held on the July 28, 2004 at the Ministry of Commerce, as stated in Annex A.

**Article 2:** All companies listed in Annex A, article 1 of this Prakas are obliged to pay additional payment of 90% before the 31st of August, 2004. The failure of this payment will be resulted in seizure of 10% deposit and the withdrawal of successful quota binding quantity for the next tender. The Ministry of Commerce reserves its own rights to prohibit those companies to participate in the next quota auctions.

**Article 3**: The Director of Cabinet, the Director General of Technical Directorate, the Director of Camcontrol Department, the Director of Trade Preferences Department, the Director of Administrative Department, all garment manufacturers and members of the Export Quota Management Committee shall effectively implement this Prakas from the date of this undersigned signature.

**Senior Minister**
**Minister of Commerce**

**CHAM PRASIDH**

C.C:
-The Cabinet of Samdech Prime Minister.
-The Cabinet of H.E DPM Sar Kheng.
-The Cabinet of H.E DPM Sok An.
-The Cabinet of H.E DPM Hor Namhong.
-Ministry of Economy and Finance.
-Ministry of Industry, Mines and Energy.
-Ministry of Labor and Vocational Training
"For information "
-Royal Gazette
-MoC Archives

ANNEX - A

ក្រសួង ពាណិជ្ជកម្ម . MINISTRY OF COMMERCE

1:55 PM, 07/28/2004

**MINISTRY OF COMMERCE**

TENDER of QUOTA

**TENDER of QUOTA**

**July 28, 2004**

| ID | COMPANY NAME | 334/634 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 14,753 | $2.00 | | | |
| 1 | Siu Quinh Garment (MFG) Ltd | 30 | $6.80 | $204.00 | $20.40 | $183.60 |
| 2 | Rao Yuan Garments | 1,053 | $5.40 | $5,686.20 | $568.62 | $5,117.58 |
| 3 | Oceanic Garment Cambodia Co. Ltd | 5,000 | $5.20 | $26,000.00 | $2,600.00 | $23,400.00 |
| 4 | Luen Thai Garment (Cambodia) | 500 | $5.00 | $2,500.00 | $250.00 | $2,250.00 |
| | **Total** | **6,583** | | **$34,390.20** | **$3,439.02** | **$30,951.18** |

| ID | COMPANY NAME | 335/635 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 5,982 | $2.00 | | | |
| 1 | Cheer View Textiles (CAM) Co., Ltd. | 480 | $16.80 | $8,064.00 | $806.40 | $7,257.60 |
| 2 | Jiangsu Diao | 1,630 | $16.60 | $27,058.00 | $2,705.80 | $24,352.20 |
| 3 | W & D (Cambodia) Co., Ltd. | 1,500 | $16.00 | $24,000.00 | $2,400.00 | $21,600.00 |
| 4 | Sin Lan Ho Garment Co., Ltd | 1,186 | $15.20 | $18,027.20 | $1,802.72 | $16,224.48 |
| 5 | QMI Industrial Co., Ltd. | 1,186 | $15.20 | $18,027.20 | $1,802.72 | $16,224.48 |
| | **Total** | **5,982** | | **$95,176.40** | **$9,517.64** | **$85,658.76** |

| ID | COMPANY NAME | 338/339 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 308,649 | $2.00 | | | |
| 1 | Tai Yang Enterprise Co., Ltd. | 30,000 | $9.00 | $270,000.00 | $27,000.00 | $243,000.00 |
| 2 | Rao Yuan Garments | 17,460 | $7.60 | $132,696.00 | $13,269.60 | $119,426.40 |
| 3 | Suntex PTE. LTD. | 40,000 | $7.00 | $280,000.00 | $28,000.00 | $252,000.00 |
| 4 | Petamon (Cambodia) Limited., | 10,000 | $7.00 | $70,000.00 | $7,000.00 | $63,000.00 |
| 5 | Gennon Garment | 30,000 | $7.00 | $210,000.00 | $21,000.00 | $189,000.00 |
| 6 | Yung Wah | 100,000 | $6.80 | $680,000.00 | $68,000.00 | $612,000.00 |
| 7 | Sun Shine Co., Ltd. | 15,000 | $6.80 | $102,000.00 | $10,200.00 | $91,800.00 |
| 8 | Grace Sun | 1,620 | $6.60 | $10,692.00 | $1,069.20 | $9,622.8.. |
| 9 | Supreme Choice (Cambodia) Garment Ltd. | 16,142 | $6.60 | $106,537.20 | $10,653.72 | $95,883.48 |
| 10 | Ming Hoi Garment | 26,904 | $6.60 | $177,566.40 | $17,756.64 | $159,809.76 |
| 11 | Kbal Koah Garment | 5,381 | $6.60 | $35,514.60 | $3,551.46 | $31,963.14 |
| 12 | Nobel Appareal Ltd. | 16,142 | $6.60 | $106,537.20 | $10,653.72 | $95,883.48 |
| | **Total** | **308,649** | | **$2,181,543.40** | **$218,154.34** | **$1,963,389.06** |

| ID | COMPANY NAME | 340/640 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 290,904 | $1.00 | | | |
| 1 | GDM | 500 | $1.00 | $500.00 | $50.00 | $450.00 |
| 2 | MSI Garment (Cambodia) Ltd | 30,000 | $1.00 | $30,000.00 | $3,000.00 | $27,000.00 |
| 3 | Enternal Way (Cambodia) Ltd | 10,000 | $1.00 | $10,000.00 | $1,000.00 | $9,000.00 |
| 4 | Roo Hsing Garment Co., Ltd. | 1,336 | $1.00 | $1,336.00 | $133.60 | $1,202.40 |
| | **Total** | **41,836** | | **$41,836.00** | **$4,183.60** | **$37,652.40** |

**ANNEX - A** ក្រសួង ពាណិជ្ជកម្ម . MINISTRY OF COMMERCE 1 55 PM 07/28/2004

## MINISTRY OF COMMERCE

TENDER of QUOTA

TENDER of QUOTA

July 28, 2004

| ID | COMPANY NAME | 345 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 6,540 | $1.00 | | | |
| 1 | High Born Enterprise Co., Ltd. | 6,540 | $3.80 | $24,852.00 | $2,485 20 | $22,366 80 |
| | **Total** | **6,540** | | **$24,852.00** | **$2,485.20** | **$22,366.80** |

| ID | COMPANY NAME | 347/348/647/648 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 82,967 | $3.00 | | | |
| 1 | Double Win | 10,000 | $13 00 | $130,000 00 | $13,000 00 | $117,000 00 |
| 2 | Min Yue Australia (Cambodia) Garment Co. | 74 | $10 40 | $769 60 | $76.96 | $692 64 |
| 3 | Sabrina | 8,000 | $10 40 | $83,200 00 | $8,320 00 | $74,883 00 |
| 4 | Hang Fung Shing | 2,550 | $10.40 | $26,520.00 | $2,652.00 | $23,868 00 |
| 5 | Evergreen Garment | 2,000 | $10.40 | $20,800.00 | $2,080 00 | $18,720 00 |
| 6 | Wearwel Cambodia Ltd. | 25,000 | $10.20 | $255,000 00 | $25,500 00 | $229,500 00 |
| 7 | QMI Industrial Co., Ltd. | 15,555 | $10 20 | $158 661 00 | $15,866 10 | $142 794 90 |
| 8 | Wing Hang Cambodia | 310 | $10 00 | $3,100 00 | $310 00 | $2,790 00 |
| 9 | Gennon Garment | 6,000 | $9 20 | $55,200 00 | $5,520 00 | $49 680 00 |
| 10 | South Bay Enterprises | 2,808 | $9 00 | $25,272 00 | $2,527 20 | $22,744 80 |
| 11 | Chu Hsing GMT | 5,616 | $9 00 | $50,544 00 | $5,054 40 | $45,489 60 |
| 12 | Top World | 1 965 | $9.00 | $17,685 00 | $1,768 50 | $15,916 50 |
| 13 | Vinstar Garment Industry Co., Ltd. | 3,089 | $9 00 | $27,801 00 | $2,780 10 | $25 020 90 |
| | **Total** | **82,967** | | **$854,552.60** | **$85,455.26** | **$769,097.34** |

| ID | COMPANY NAME | 352/652 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 174,649 | $0.40 | | | |
| 1 | Manhattan Textile & Garment Corp. | 700 | $1 40 | $980 00 | $98 00 | $882 00 |
| 2 | Vivatino Design (Cambodia) PTE., LTD | 10,000 | $1 20 | $12,000 00 | $1,200 00 | $10 800 00 |
| 3 | Luen Thai Garment (Cambodia) | 800 | $1 20 | $960 00 | $96.00 | $864 00 |
| 4 | Gennon Garment | 900 | $1 00 | $900 00 | $90 00 | $810 00 |
| 5 | Roo Hsing Garment Co., Ltd. | 2,400 | $1 00 | $2,400 00 | $240 00 | $2,160 00 |
| 6 | New Orient (Cambodia) Garment Co., Ltd. | 10,000 | $0 80 | $8,000 00 | $800 00 | $7,200 00 |
| 7 | Supreme Garments PTE., LTE. | 4,300 | $0.80 | $3,440 00 | $344 00 | $3,096 00 |
| 8 | Honey Wear Garments Co., Ltd. | 2,178 | $0 80 | $1,742 40 | $174.24 | $1,568 16 |
| 9 | New Point World Trade | 10,000 | $0.80 | $8,000.00 | $800.00 | $7,200 00 |
| 10 | Tai Yang Enterprise Co., Ltd. | 1,200 | $0 80 | $960.00 | $96 00 | $864 00 |
| 11 | Kingsland Garment | 30,000 | $0.60 | $18,000 00 | $1,800 00 | $16,200 00 |
| 12 | Enternal Way (Cambodia) Ltd | 17,300 | $0 60 | $10,380.00 | $1,038 00 | $9,342 00 |
| 13 | Sin Lan Ho Garment Co., Ltd | 20,000 | $0.40 | $8,000.00 | $800 00 | $7,200.00 |
| | **Total** | **109,778** | | **$75,762.40** | **$7,576.24** | **$68,186.16** |

| ID | COMPANY NAME | 438 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 38,614 | $1.00 | | | |
| 1 | Cambodian Hoi Fu | 3,000 | $2 00 | $6,000 00 | $600 00 | $5,400.00 |
| | **Total** | **3,000** | | **$6,000.00** | **$600.00** | **$5,400.00** |

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

1 55 PM, 07/28/2004

**MINISTRY OF COMMERCE**

TENDER of QUOTA

**TENDER of QUOTA**

**July 28, 2004**

| ID | COMPANY NAME | 445/446 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **61,701** | **$0.50** | | | |
| 1 | QMI Industrial Co., Ltd. | 85 | $0.50 | $42.50 | $4.25 | $38.25 |
| | Total | **85** | | **$42.50** | **$4.25** | **$38.25** |

| ID | COMPANY NAME | 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **438,927** | **$1.00** | | | |
| 1 | San Lei Fung | 1,550 | $2.20 | $3,410.00 | $341.00 | $3,069.00 |
| 2 | Yubin Service Co., Ltd. | 5,000 | $2.20 | $11,000.00 | $1,100.00 | $9,900.00 |
| 3 | PCCS Garments Ltd. | 2,400 | $2.00 | $4,800.00 | $480.00 | $4,320.00 |
| 4 | Sin Lan Ho Garment Co., Ltd | 12,000 | $1.60 | $19,200.00 | $1,920.00 | $17,280.00 |
| 5 | Terratex Knitting & GMT | 2,560 | $1.60 | $4,096.00 | $409.60 | $3,686.40 |
| 6 | Rao Yuan Garments | 41,790 | $1.60 | $66,864.00 | $6,686.40 | $60,177.60 |
| 7 | Ya Shin Industries Co., Ltd | 30,000 | $1.60 | $48,000.00 | $4,800.00 | $43,200.00 |
| 8 | M & V Int'l MFG LTD. | 4,500 | $1.60 | $7,200.00 | $720.00 | $6,480.00 |
| 9 | Yung Wah | 80,000 | $1.60 | $128,000.00 | $12,800.00 | $115,200.00 |
| 10 | Double Win | 3,300 | $1.60 | $5,280.00 | $528.00 | $4,752.00 |
| 11 | Hung Wah Cambodia Garment Maf. Ltd. | 10,000 | $1.40 | $14,000.00 | $1,400.00 | $12,600.00 |
| 12 | Cambo Fashion Co., Ltd. | 40,000 | $1.40 | $56,000.00 | $5,600.00 | $50,400.00 |
| 13 | Chean Ping Garment Co., Ltd. | 10,000 | $1.20 | $12,000.00 | $1,200.00 | $10,800.00 |
| 14 | Cambo Swim Co., Ltd. | 10,000 | $1.20 | $12,000.00 | $1,200.00 | $10,800.00 |
| 15 | New Orient (Cambodia) Garment Co., Ltd. | 1,000 | $1.00 | $1,000.00 | $100.00 | $900.00 |
| 16 | Great Lancelot International Co., Ltd. | 7,000 | $1.00 | $7,000.00 | $700.00 | $6,300.00 |
| 17 | South Bay Enterprises | 700 | $1.00 | $700.00 | $70.00 | $630.00 |
| 18 | YGM (Cambodia) Ltd. | 3,500 | $1.00 | $3,500.00 | $350.00 | $3,150.00 |
| 19 | QMI Industrial Co., Ltd. | 15,000 | $1.00 | $15,000.00 | $1,500.00 | $13,500.00 |
| 20 | Goldfame Enterprises | 20,000 | $1.00 | $20,000.00 | $2,000.00 | $18,000.00 |
| | Total | **300,300** | | **$439,050.00** | **$43,905.00** | **$395,145.00** |

| ID | COMPANY NAME | 645/646 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | **250,104** | **$0.60** | | | |
| 1 | D.A. Corporation, Ltd. | 1,600 | $0.60 | $960.00 | $96.00 | $864.00 |
| | Total | **1,600** | | **$960.00** | **$96.00** | **$864.00** |

| | | | | |
|---|---|---|---|---|
| **Sub-TOTAL** | | **$3,754,165.50** | **$375,416.55** | **$3,378,748.95** |